ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៙៙៙៙៙

តុលាការកំពូល
-------

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៤
ចុះថ្ងៃទី២២-៦-១៩៩៩

សាលដីកា
លេខ : ៣១
ចុះថ្ងៃទី១៣-១០-១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រមរបាយការណ៍
៣- លោក សោម សិរីវឌ្ឍ ចៅក្រម
៤- លោក ប្រាក់ គឹមសាន ចៅក្រម
៥- លោក យស់ សួខឡឹន ចៅក្រម

លោក ប៉ុល វណ្ណា ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ០២-៤-១៩៩៩ពីសាលដីកាព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ១២-០២-១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី ២២-៦-១៩៩៩ របស់តុលាការកំពូល ។

ពីបទ : ប្រើប្រាស់អាវុធខុសច្បាប់ និង បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ១២-១០-៩៧ តាមមាត្រា ៥៤, ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះអៀ វុធ ហៅ អូន ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីលំនៅ ផ្ទះលេខ ៨អឺ០ ផ្លូវ ១៤៦ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

- ឈ្មោះ អ៊ុក ម៉ាក់ថៃ " ម្ចាស់បណ្តឹងសាទុក្ខ " ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ ជាម្តាយជនជាប់ចោទ និងជាអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី មានទីលំនៅផ្ទះលេខ ៨អឺ០ ផ្លូវ១៤៦ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

- មេធាវី លោក ចាយ ច័ន្ទតារាវណ្ណ

- ជនរងគ្រោះឈ្មោះ ម៉ា បូ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ៅ ទ្រី " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ២០៩៤ ក្រុម៥៩ សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ

- មេធាវី លោក ទូត លុច

- តាមពាក្យបណ្តឹងចុះថ្ងៃទី ១២ - ១២ - ៨៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ៅ ស្រី ប្តឹងពីឈ្មោះ អៀង នរិទ្ធ ពីបទ : មនុស្សឃាតដោយចេតនា មកលើប្អូនរបស់ខ្លួន ឈ្មោះ ម៉ា បូ ខ្លួន សុំទាមទារថ្លៃថ្នាំពេទ្យព្យាបាល និង ជំងឺចិត្ត ចំនួន ១៥.០០០ ដុល្លារអាមេរិក ។

- បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ថា : ស្នងតាមរយៈសវនាការមកក្នុងនាមអយ្យការសូមចោទប្រកាន់ជនជាប់ចោទឈ្មោះ អៀង នរិទ្ធ ហៅ អួន ពីបទ : ប្រើប្រាស់អាវុធខុសច្បាប់ និង បង្ករបួសស្នាមដោយចេតនា លើ ឈ្មោះ ម៉ា បូ ប្រព្រឹត្ត កាលពីថ្ងៃទី ១២ - ១០ - ១៩៨៧ នៅក្រុងភ្នំពេញ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយ ផ្តន្ទាទោសតាមមាត្រា៥៤ - ៤១ - ៦៨ និង មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៥ " ៩ " ចុះថ្ងៃទី ១១ - ៣ - ១៩៨៨ របស់តុលាការ ក្រុងភ្នំពេញ ដែលបានសំរេច :

១ - ផ្តន្ទាទោស ឈ្មោះ អៀង នរិទ្ធ ហៅអួន អាយុ ១៥ឆ្នាំ ដាក់ ពន្ធនាគារចំនួន០៣ខែ តែទោសនេះត្រូវព្យួរដោយមានរយៈពេលសាកល្បង ២ឆ្នាំ ៦ខែ ចាប់តាំងពីថ្ងៃប្រកាសសាលក្រម តទៅ ។ ពីបទ ប្រើប្រាស់អាវុធខុសច្បាប់ និង បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តកាលពីថ្ងៃទី ១២ - ១០ - ១៩៨៧ នៅក្រុងភ្នំពេញ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោស តាមមាត្រា៥៤ , ៤១ , ៦៨ និងមាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - បង្គាប់អោយឈ្មោះ អ៊ុក ម៉ាក់ថៃ សងសំណងការព្យាបាលបន្ថែមចំនួន ៥០០០ដុល្លារអាមេរិក និងជំងឺចិត្ត ៣០០០ដុល្លារអាមេរិក អោយទៅឈ្មោះ ម៉ៅ ស្រី ជាដើមបណ្តឹងរដ្ឋប្បវេណីចាប់ពីថ្ងៃ សាលក្រមស្ថាពរ ។ សំណងលើសពីនេះលើកចោល ។

ករណីទីងទឹងពុំព្រមសងត្រូវដាក់គុកបង្ខំដល់រូបកាយឈ្មោះ អៀង នរិទ្ធ ដើម្បីទារប្រាក់សំណង ធនទណ្ឌគ្រប់ចំនួនខាងលើទៅតាមច្បាប់ស្តីពីការ ដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣ - វត្ថុតាងមាន កាំភ្លើងខ្លីម៉ាក កា៥៩ លេខ ១៦០២ មួយដើម និងបង់គ្នានគ្រាប់១ ត្រូវ រឹបអូសជាសម្បត្តិរដ្ឋ ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទឈ្មោះ អៀង នរិទ្ធ ចំពោះ មុខដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ។ ភាគីណាមិនសុខចិត្តពីសាលក្រមនេះមាន សិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល២ខែ ចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី ២៧ - ៤ - ១៩៨៨ របស់ឈ្មោះអ៊ុក ម៉ាក់ថៃ ប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ០៥ " ៩ " ចុះថ្ងៃទី ១១ - ៣ - ១៩៨៨ របស់តុលាការក្រុងភ្នំពេញ នៃសាលក្រមទាំងមូល និងបណ្តឹងឧទ្ធរណ៍លេខ០៦ ចុះថ្ងៃទី២៨ - ៤ - ១៩៨៨របស់ឈ្មោះម៉ៅ ស្រី ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអម សាលាឧទ្ធរណ៍ ថា :

១ - ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ អ៊ុក ម៉ាក់ថៃ ជាម្តាយជនជាប់ចោទ ទុកជាត្រឹមត្រូវតាម ទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹងនិតិច្បាប់ ។

---- ៣ ----

២ - ទទួលបណ្ដឹងឧទ្ធរណ៍ របស់ឈ្មោះ ម៉ៅ ស្រី ជាដើមបណ្ដឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣ - បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ០៥ " ជ " ចុះថ្ងៃទី ១១ - ៣ - ៩៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ដោយកែប្រែបទល្មើសពីបទ : បង្ករបួសស្នាមដោយចេតនា មកបទល្មើសប៉ុនប៉ងធ្វើមនុស្សឃាដដោយចេតនាមានអាវុធ និង ប្រើប្រាស់អាវុធខុសច្បាប់តាមមាត្រា ៣២ និង ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង បន្ថែមសំណងពន្យាបាលបន្ថែមទៀត ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ១២ - ០២ - ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចថា :

១ - ទទួលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ អ៊ុច ម៉ាក់ថៃ ប្ដឹងជនល្មើស ចុះថ្ងៃទី ២៧ - ៤ - ៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែបដិសេធចោលដោយខ្វះមូល និង គតិច្បាប់ ។

២ - ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ - ៥ - ៩៨ របស់ឈ្មោះ ម៉ៅ ស្រី " ដើមបណ្ដឹងរដ្ឋប្បវេណី " ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥ " ជ " ចុះថ្ងៃទី ១១ - មិនា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដោយគ្រាន់តែកែប្រែចំនុចទី២ នៃសាលក្រមថា បង្គាប់អោយឈ្មោះ អ៊ុក - ម៉ាក់ថៃ សងថ្លៃពន្យាបាល និង ជំងឺចិត្តសរុបចំនួន ១២០០០ដុល្លា " មួយម៉ឺនពីរពាន់ដុល្លាអាមេរិក " ។

៤ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខ គូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ០២ - ៤ - ១៩៩៩ របស់ឈ្មោះអ៊ុក ម៉ាក់ថៃ ប្ដឹងពីសាលដីកាព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ១២ - ០២ - ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ២៦ - ៧ - ១៩៩៩ របស់អ្នកស្រី អ៊ុក ម៉ាក់ ដែលជាអ្នកទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី ។

- បានឃើញសារណាតប ចុះថ្ងៃទី ០៩ - ៨ - ១៩៩៩ របស់ឈ្មោះ ម៉ៅ ប៊ូ ជាជនរងគ្រោះ ។

- បានឃើញ ពាក្យសុំដកបណ្ដឹងសាទុក្ខចុះថ្ងៃទី ០៥ - ១០ - ១៩៩៩ របស់អ្នកស្រីអ៊ុក ម៉ាក់ - ថៃ សុំដកបណ្ដឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ០២ - ៤ - ១៩៩៩ ។

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១ - ទទួលពាក្យបណ្ដឹងសុំដកបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ០៥ - ១០ - ១៩៩៩ របស់អ្នកស្រី អ៊ុក ម៉ាក់ថៃ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២ - អនុញ្ញាតិតាមពាក្យសុំដកបណ្ដឹងសាទុក្ខរបស់អ្នកស្រី អ៊ុក ម៉ាក់ថៃ ។

- បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ុក ម៉ាក់ទ៉ៃ ថា ៖ សូមឯកឧត្តមមេត្តាអនុញ្ញាតអោយនាងខ្ញុំដកពាក្យបណ្តឹងសាទុក្ខរបស់នាងខ្ញុំវិញ ។

- បានស្តាប់ចម្លើយឈ្មោះ ម៉ៅ ទ្រី ដើមបណ្តឹងរដ្ឋប្បវេណី ថា ៖ សូមតុលាការអនុញ្ញាតតាមពាក្យសុំរបស់អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃចុះ ។

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីលោកចាយ ច័ន្ទតារាវណ្ណ ការពារអោយជនជាប់ចោទ ថា ៖ សូមតុលាការមេត្តាអនុញ្ញាតអោយកូនក្តីរបស់ខ្ញុំសុំដកបណ្តឹងសាទុក្ខវិញដោយអនុគ្រោះ

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវី លោក ទួត លុច ការពារអោយដើមបណ្តឹងរដ្ឋប្បវេណី ថា ៖ សូមតុលាការសំរេចតាមនីតិវិធី ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ ថា ៖ សូមតុលាការសំរេចតាមនីតិវិធី ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី របស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ និង របស់មេធាវីជនរងគ្រោះ

- ក្រោយពីបានឃើញពាក្យបណ្តឹងសុំដកបណ្តឹងសាទុក្ខរបស់អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃ អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី និងជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មុនដំណាក់កាលប្រកាសសាលដីកា អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃ អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ជាម្ចាស់បណ្តឹងសាទុក្ខ បានប្តឹងសុំដកបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ តាមពាក្យ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៩ របស់ខ្លួនវិញ ដោយអ្នកស្រី និង លោក ម៉ៅ ទ្រី ដើមបណ្តឹងរដ្ឋប្បវេណី បានព្រមព្រៀងឯកភាពគ្នាតាមកំណត់ហេតុសំរុះសំរួល ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ដែលគប្បីតុលាការកំពូលអនុញ្ញាតតាមសុំ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណី

១- ទទួលពាក្យបណ្តឹងសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ របស់អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- អនុញ្ញាតអោយ អ្នកស្រី អ៊ុក ម៉ាក់ទ៉ៃ ដកបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី

០២ ខែ មេសា ឆ្នាំ ១៩៩៩ របស់ខ្លួនតាមសុំ ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌ លេខ ៣៥ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីចាត់ការតាមនីតិវិធី ។

៤ - សាលដីកានេះប្រកាស នាសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែ - តុលា ឆ្នាំ ១៩៩៩ ។